## រឿងទី៤៖ សាឡូម៉ូន

**ខគម្ពីរ៖ ១ពង្សាវតាក្សត្រ៣៖៩-១០**

ហេតុនេះ សូមព្រះអង្គប្រោសប្រទានឲ្យទូលបង្គំមានប្រាជ្ញាឈ្លាសវៃ ដើម្បីគ្រប់គ្រងប្រជារាស្ត្ររបស់ព្រះអង្គ ហើយឲ្យទូលបង្គំចេះវិនិច្ឆ័យ ស្គាល់ការល្អ ការអាក្រក់ បើមិនដូច្នោះទេ តើនរណាអាចគ្រប់គ្រងលើប្រជារាស្ត្រដ៏ច្រើនឥតគណនារបស់ព្រះអង្គបាន?»។ ព្រះអម្ចាស់សព្វព្រះហឫទ័យនឹងការទូលសូមរបស់ព្រះបាទសាឡូម៉ូនណាស់

សាឡូម៉ូនស្តេចស្រុកអ៊ីស្រាអែលទ្រង់គោរពស្រឡាញ់ព្រះជាម្ចាស់ខ្លាំងដូចស្តេចដាវីឌដែរ។
នៅពេលនោះ ស្រុកអ៊ីស្រាអែលគឺមិនទាន់សាងសង់ព្រះវិហារសម្រាប់ព្រះនាមព្រះជាម្ចាស់នៅឡើយទេ។
ដូច្នេះ រាស្ត្រអ៊ីស្រាអែលទាំងអស់ ត្រូវទៅថ្វាយបង្គំព្រះជាម្ចាស់នៅតាមទួលខ្ពស់(ទីសក្ការៈដែលនៅទីខ្ពស់)។
នៅថ្ងៃមួយ ព្រះបាទសាឡូម៉ូនទ្រង់បានយាងទៅគីបៀនដើម្បីថ្វាយបង្គំព្រះជាម្ចាស់។
នៅទីនោះ មានទីសក្ការៈដ៏ធំមួយ។ ព្រះបាទសាឡូម៉ូន បានថ្វាយដង្វាយដុតនៅលើទីសក្ការៈនោះចំនួន១ពាន់។
ព្រះជាម្ចាស់បានទទួលយកយញ្ញបូជានោះដោយអំណរ។ មានថ្ងៃមួយ ព្រះជាម្ចាស់បានលេចមកក្នុងសុបិនរបស់ព្រះបាទសាឡូម៉ូន។
«សាឡូម៉ូនអើយ តើឯងចង់បានអ្វី?»
ស្តេចសាឡូម៉ូនតបទៅព្រះជាម្ចាស់ថា៖ «សូមប្រទានប្រាជ្ញាដល់ទូលបង្គំ ដើម្បីឱ្យទូលបង្គំអាចគ្រប់គ្រងមើលថែរាស្ត្ររបស់ព្រះជាម្ចាស់បានយ៉ាងល្អផង»។
ព្រះជាម្ចាស់សព្វព្រះទ័យជាខ្លាំងចំពោះការឆ្លើយតបរបស់ព្រះបាទសាឡូម៉ូន។
ពេលនោះ មានស្ត្រីពីរនាក់ បានយកកូនម្នាក់មកឈរនៅចំពោះព្រះបាទសាឡូម៉ូន។
ស្ត្រីទាំងពីរនាក់នោះ មានទំនាស់និងដោយសារដណ្តើមកូនគ្នា។
ព្រះបាទសាឡូម៉ូន បានគិតមួយសន្ទុះ ក៏បានកាត់ក្តីដោយប្រាជ្ញាញាណមកពីព្រះជាម្ចាស់។
«ចូរយកកូនដែលនៅរស់នោះមកកាត់ជាពីរ ហើយយកមួយចំហៀងឱ្យទៅស្ត្រីម្នាក់នេះ ហើយមួយចំហៀងទៀត ឱ្យទៅស្ត្រីម្នាក់នោះទៅ»
មនុស្សម្នាមានការភ្ញាក់ផ្អើលជាខ្លាំង។ ស្រាប់តែពេលនោះ មានស្ត្រីម្នាក់ចេញមកនិយាយទាំងទឹកភ្នែកថា៖
«កុំអី! កុំសម្លាប់កូននេះអី ទុកឱ្យកូននេះទៅស្ត្រីម្នាក់នោះចុះ»
ប៉ុន្តែ ចំណែកស្ត្រីម្នាក់ទៀត បែរជានិយាយថា៖
«ចូរធ្វើដូច្នោះចុះ កាត់កូននេះជាពីរទៅ! ធ្វើដូច្នេះ កូននេះនឹងមិនត្រូវបានជារបស់ខ្ញុំ ឬរបស់ស្ត្រីនោះឡើយ»







បន្តិចក្រោយមក ស្តេចសាឡូម៉ូនដែលមានពេញដោយប្រាជ្ញាញាណ ក៏បានកាត់ក្តីចុងក្រោយថា៖

«ចូរយកកូននោះឱ្យទៅស្ត្រីដែលសុំកុំឱ្យសម្លាប់នោះទៅ! ដ្បិតស្ត្រីនោះគឺជាម្តាយដែលស្រឡាញ់កូនរបស់ខ្លួនខ្លាំង ណាស់»

ការនេះ ធ្វើឱ្យព្រះបាទសាឡូម៉ូនអាចកាត់ក្តីប្រកបដោយប្រាជ្ញាញាណដែលព្រះជាម្ចាស់បានប្រទានមកបាន។

ស្តេចសាឡូម៉ូន បានគ្រប់គ្រងនិងដឹកនាំប្រជារាស្ត្រទាំងអស់ដោយប្រាជ្ញាញាណ ធ្វើឱ្យប្រទេសជាតិមានសុខ សន្តិភាព។

ដំណឹងនេះ បានលេចឮទៅដល់ប្រទេសជិតខាង ធ្វើឱ្យពួកគេមានការច្រណែននឹងស្តេចសាឡូម៉ូនជាខ្លាំង។

ដូច្នេះ មានមនុស្សជាច្រើនបានធ្វើដំណើរមកជួបស្តេចសាឡូម៉ូន។

សូម្បីតែមហាក្សត្រីនៃស្រុកសេបាក៏យាងមកស្រុកអ៊ីស្រាអែល ដើម្បីជួបជាមួយព្រះបាទសាឡូម៉ូន ដោយបាននាំយកនូវមាសនិងប្រាក់ ព្រមទាំងត្បូង គ្រឿងក្រអូបជាច្រើនដាក់តាមសត្វអូដ្ឋមកជាមួយដែរ។

មហាក្សត្រីស្រុកសេបាដែលបានចាកចេញពីស្រុកកំណើតដ៏ឆ្ងាយមកស្រុកអ៊ីស្រាអែលដើម្បីចង់ល្បងលប្រាជ្ញារបស់ ព្រះបាទសាឡូម៉ូនបានសួរសំណួរទៅព្រះបាទសាឡូម៉ូន។

ព្រះបាទសាឡូម៉ូនបានឆ្លើយនឹងសំណួរទាំងនោះយ៉ាងក្បោះក្បាយ។

មហាក្សត្រីស្រុកសេបាក៏មានការអស្ចារ្យចំពោះប្រាជ្ញាញាណរបស់ព្រះបាទសាឡូម៉ូនជាខ្លាំង ហើយក៏សរសើរតម្កើង ព្រះជាម្ចាស់ដែលប្រទានប្រាជ្ញាដល់ស្តេច។

ព្រះបាទសាឡូម៉ូន បានសម្រេចធ្វើការសាងសង់ដំណាក់របស់ព្រះជាម្ចាស់។

ដំណាក់ព្រះជាម្ចាស់នេះ ត្រូវបានប្រជារាស្ត្រអ៊ីស្រាអែលសាងសង់យ៉ាងអស់ពីចិត្ត និងដោយក្តីស្រឡាញ់អស់រយៈ ពេលប្រាំពីរឆ្នាំ។

ក្រោយពីព្រះបាទសាឡូម៉ូនអធិស្ឋានទៅព្រះជាម្ចាស់រួចហើយ ទ្រង់បានលើកដៃទាំងពីរឡើង ដើម្បីប្រសិទ្ធពរដល់ ប្រជារាស្ត្រទាំងអស់





**សកម្មភាពទី១** ចូរសរសេរលេខតាមលំដាប់លំដោយនៃរឿងដែលបានរៀននៅថ្ងៃនេះ។



ពេលនោះ
ស្ត្រីម្នាក់បានយំហើយនិយាយថា៖
«សូមមេត្តា! កុំសម្លាប់ទារកនេះអី! ខ្ញុំសុខ
ចិត្តឱ្យទារកនេះទៅស្ត្រីនោះចុះ!»



8

ស្ដេចសាឡូម៉ូនបានគ្រប់គ្រងប្រជារាស្ត្រ
ដោយប្រាជ្ញា ធ្វើឱ្យប្រទេសមានសន្តិភាព។



ថ្ងៃមួយ មានស្ត្រីពីរនាក់បានបីទារកម្នាក់
ចូលមកគាល់ស្ដេចសាឡូម៉ូន។



ស្ដេចសាឡូម៉ូនបានគិតមួយសន្ទុះ
រួចបានកាត់ក្ដីយ៉ាងអស្ចារ្យ
ដោយប្រាជ្ញារបស់ព្រះជាម្ចាស់។



«ចូរប្រគល់ទារកនោះទៅឱ្យស្ត្រីដែលសុំ
ឱ្យទុកជីវិតវាទៅ! នាងជាម្ដាយពិតប្រាកដ
ដែលស្រឡាញ់ទារកនោះ!»



1

ស្ដេចសាឡូម៉ូនបានសូមប្រាជ្ញាពីព្រះជា
ម្ចាស់ ដើម្បីគ្រប់គ្រងប្រទេសឱ្យបានល្អ។



«ចូរកាប់កូននេះជាពីរចំណែក ហើយ
ចែកមួយចំហៀងម្នាក់ៗឲ្យស្ត្រីទាំងពីរចុះ»។



ហើយស្ត្រីទាំងពីរបានឈ្លោះប្រកែកគ្នា
ថាទារកដែលរស់នោះជាកូនរបស់ខ្លួន។

## សកម្មភាពទី២ សូមឆ្លើយសំណួរខាងក្រោម។

a. តើស្តេចសាឡូម៉ូនបានទូលសូមអ្វីពីព្រះជាម្ចាស់? ហេតុអ្វីបានជាទ្រង់សូមដូច្នេះ?

---

b. ស្តេចសាឡូម៉ូនបានសម្រេចព្រះទ័យសាងសង់ព្រះវិហារថ្វាយព្រះជាម្ចាស់។ តើការសាងសង់ព្រះវិហារនោះចំណាយពេលអស់ប៉ុន្មានឆ្នាំ?

---

c. សូមអានពង្សាវតា៣៖៤-១៥ រួចឆ្លើយសំណួរ។ ព្រះជាម្ចាស់សព្វព្រះទ័យនឹងអ្វីដែលស្តេចសាឡូម៉ូនបានទូលសូម។ ដូច្នេះ តើព្រះជាម្ចាស់បានមាន ព្រះបន្ទូលដូចម្តេចទៅកាន់ស្តេចសាឡូម៉ូន?



---

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (១ពង្សាវតាក្សត្រ៣៖៩-១០)

| ព្រះអម្ចាស់សព្វព្រះហឫទ័យនឹងការទូលសូមរបស់ព្រះបាទសាឡូម៉ូនណាស់ |
|---|

